# សេចក្តីថ្លែងការណ៍ របស់អង្គការមិនមែនរដ្ឋាភិបាល ទៅកាន់ វេទិកា កិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍កម្ពុជា ឆ្នាំ ២០០៧

**ភ្នំពេញ. ១៩-២០ ខែមិថុនា ឆ្នាំ ២០០៧**

# មាតិកា


**១. សេចក្តីផ្តើម........................................................................២**

**២. បញ្ហាអាទិភាព......................................................................៣**

**២.១ ដី កសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ...........................................៣**

**២.២ អភិបាលកិច្ចល្អ.....................................................................៦**

**២.៣ ការអភិវឌ្ឍន៍ធនធានមនុស្ស..........................................................៩**

**៣. ផែនការអនាគត....................................................................១២**


## ១. សេចក្តីផ្តើម

ការងាររបស់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនៅប្រទេសកម្ពុជា បានគ្របដណ្តប់ទៅលើបញ្ហាអភិវឌ្ឍន៍យ៉ាងទូលំទូលាយ និងបានផ្សារភ្ជាប់យ៉ាងជិតស្និតជាមួយជីវិត និងស្ថានភាពរស់នៅរបស់ប្រជាជនកម្ពុជា។ មូលដ្ឋានរួមរបស់អង្គការទាំងអស់គឺក្នុងគោលបំណងរួមដើម្បីលើកកំពស់តួនាទីរបស់ជនក្រីក្រ និងក្រុមងាយរងគ្រោះនៅក្នុងសង្គមកម្ពុជា។ តាមរយៈការរួមបញ្ចូលគ្នានូវចំណេះដឹងពីថ្នាក់មូលដ្ឋាន អង្គការសង្គស៊ីវិលមានតួនាទីយ៉ាងសំខាន់ក្នុងការជួយរាជរដ្ឋាភិបាលកម្ពុជា រៀបចំធ្វើគោលនយោបាយ ដោយធ្វើការចែករំលែក និងផ្តល់ពត៌មានត្រលប់ និងសំណូមពរទាំងឡាយទាក់ទង់នឹងគោលនយោបាយអភិវឌ្ឍន៍ និងការអនុវត្តន៍គោលនយោបាយ។

សេចក្តីថ្លែងការណ៏របស់អង្គការមិនមែនរដ្ឋាភិបាលទៅកាន់ វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាឆ្នាំ ២០០៧ បានកំណត់យកបញ្ហាអាទិភាពចំនួនបីគឺ : ដីកសិកម្ម និងធនធានធម្មជាតិ ការអភិវឌ្ឍន៍ធនធានមនុស្ស និងអភិបាលកិច្ចល្អ ក្នុងនោះការអភិវឌ្ឍន៍គោលនយោបាយសមស្រប និងរាល់កម្មវិធីកំណែទម្រង់មានសក្តានុពលខ្លាំងក្នុងការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាក្រីក្រ និងងាយរងគ្រោះរាប់លាននាក់។ ភាគច្រើននៃគោលនយោបាយ និងកម្មវិធីកំណែទម្រង់ទាំងនេះ សុទ្ធសឹងតែមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០។

បន្ថែមលើសេចក្តីថ្លែងការណ៏នេះ អង្គការមិនមែនរដ្ឋាភិបាល បានរៀបចំឯកសារស្តីពីគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាលចំនួន ២៣ វិសយ័ ស្តីអំពីការអភិវឌ្ឍន៍របស់កម្ពុជាក្នុងឆ្នាំ២០០៦ ក្នុងគោលបំណងផ្តល់ព័តិមានត្រឡប់ក្នុងន័យស្ថាបនាលើវឌ្ឍនភាព នៃការអនុវត្តន៏ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងសូចនាករតាមដានរួមក្នុងឆ្នាំ២០០៦។ ឯកសារដែលបានបោះពុម្ពផ្សាយទាំងនេះ មានឈ្មោះថា **"ឯកសារស្តីពីគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាល ស្តីអំពីការអភិវឌ្ឍន៍របស់កម្ពុជា ក្នុងឆ្នាំ២០០៦"** ដែលជាឯកសារគោលនៃសេចក្តីថ្លែង

ការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលនេះ។ ឯកសារនេះត្រូវបានរៀបចំដាក់បញ្ចូលដាច់ពីគ្នា ទៅកាន់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា។

## ២. បញ្ហាអាទិភាព

- ផ្នែក**ដីកសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ** ផ្តោតជាសំខាន់លើការអភិវឌ្ឍន៍បច្ចុប្បន្នដែលបង្កគ្រោះថ្នាក់ជាពិសេសដល់ប្រជាជនក្រីក្រ និងក្រុមងាយរងគ្រោះដូចជាការបាត់បង់ដីធ្លី ការរុះរើទីលំនៅដោយបង្ខំ និងភាពកាន់តែបាត់បង់សិទ្ធិក្នុងការទទួលបានដីធ្លី និងប្រើប្រាស់ធនធានធម្មជាតិ ។
- ផ្នែក**ការអភិវឌ្ឍន៍ធនធានមនុស្ស** គ្របដណ្តប់ទៅលើវិស័យអប់រំ សុខាបាល និង យេនឌ័រ។
- ផ្នែក**អភិបាលកិច្ចល្អ** រៀបរាប់ពីការព្រួយបារម្ភរបស់អង្គការមិនមែនរដ្ឋាភិបាល ស្តីអំពីពង្រាងច្បាប់ប្រឆាំងអំពើពុករលួយ សេរីភាពពតិមាន ការគ្រប់គ្រងចំណូលប្រេងនាថ្ងៃអនាគត និងកំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ ។

### *២.១ ដី កសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ*

អង្គការមិនមែនរដ្ឋាភិបាលមានការព្រួយបារម្ភយ៉ាងខ្លាំង ពីការកើនឡើងនៃចំនួនប្រជាជនក្រីក្រ និងងាយរងគ្រោះទាំងនៅទីក្រុង និងនៅជនបទដែលកំពុងបន្តបាត់បងដីធ្លី និងធនធានធម្មជាតិ ។

ការព្រួយបារម្ភជាពិសេសនោះគឺការកើនឡើងនៃចំនួនប្រជាជន ដែលកំពុងរងនូវការ**រុះរើទីលំនៅដោយបង្ខំ** ដែលបណ្តាលមកពីការវិនិយោគ និងគំរោងអភិវឌ្ឍន៍នានា និងការទទួលរងនូវការគំរាមកំហែងអំពើហិង្សា និងទង្វើអមនុស្សធម៌មួយចំនួនក្នុងពេលបណ្តេញចេញ។ សំរាប់ប្រជាជននៅតំបន់ទីក្រុងទោះបីគេមានឯកសារដែលបញ្ជាក់ពីកម្មសិទ្ធិស្របច្បាប់ក្តី ក៏ពួកគេត្រូវទទួលរងនូវការបណ្តេញចេញដោយបង្ខំ ហើយអោយទៅរស់នៅតំបន់តាំងទីលំនៅថ្មី ដែលពុំមានសេវាសាធារណៈគ្រប់គ្រាន់ដូចជាទឹក និងមិនមានអនាម័យមិនតែប៉ុណ្ណោះ ពួកគេទទួលបានតិចតួចបំផុត ឬមិនទទួលបានសោះនូវឱកាសមានការងារធ្វើ សេវាអប់រំ និងសេវាសុខភាព។ នេះគឺជាការដើរថយក្រោយមួយនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល បើធៀបទៅនឹងគោលនយោបាយសំរាប់ការតាំងទីលំនៅថ្មីកាលពីឆ្នាំ១៩៩៨ និងឆ្នាំ២០០០ ដែលកាលណោះបានផ្តល់ជំរកសមរម្យ និងមានលក្ខណៈមនុស្សធម៌ អោយប្រជាពលរដ្ឋនៅតំបន់អភិវឌ្ឍន៍មានជ័យ និងគោកឃ្លាំង។ ជាជាងធ្វើអោយដំណោះស្រាយតាំងទីលំនៅថ្មីមានភាពប្រសើរឡើងដោយផ្តើមចេញពីបទពិសោធន៍ចាស់ៗកន្លងមក រាជរដ្ឋាភិបាលបានបណ្តោយអោយបញ្ហានេះក្លាយទៅជាទុក្ខវេទនាដ៏មិនគួរអោយកើតមានសំរាប់ប្រជាពលរដ្ឋកម្ពុជារាប់ពាន់គ្រួសារ ខណៈពេលដែលក្រុមហ៊ុនអភិវឌ្ឍន៍ទទួលបានប្រាក់ចំណេញយ៉ាងច្រើនសន្ធឹកសន្ធាប់។

រីឯនៅតាមទីជនបទវិញ ទោះជាកន្លងមកភស្តុតាងដែលបញ្ជាក់ថា ការបង្កើតការជួយគាំទ្រដល់កសិករខ្នាតតូច គឺជាមធ្យោបាយល្អបំផុតក្នុងការបង្កើនផលិតភាព និងលើកកំពស់ជីវភាពប្រជាជនជនបទ[1] ក៏ដោយ ក៏រាជ

[1] ធនាគារពិភពលោក (២០០៦), កម្ពុជា: កាត់បន្ថយពាក់កណ្តាលនៃភាពក្រីក្រនៅត្រឹមឆ្នាំ២០១៥។ ការវាយតំលៃភាពក្រីក្រឆ្នាំ២០០៦។ របាយការណ៍លេខ ៣៥២១៣-KH ធនាគារពិភពលោកអាស៊ីបូពា៌ និងតំបន់ប៉ាស៊ីហ្វិក ខែកុម្ភៈ ២០០៧ ទំព័រ៨៧។

រដ្ឋាភិបាលកម្ពុជា បែរជាប្រគល់ផ្ទៃដីមួយផ្នែកធំនៃប្រទេសអោយទៅអ្នកវិនិយោគទុន ក្រោមកិច្ចសន្យាជួលរយៈពេល ៧០ឆ្នាំ (ឬយូរជាងនេះ) តាមរយៈរូបភាពនៃការផ្តល់សម្បទានដីសេដ្ឋកិច្ចដោយពុំអនុវត្តតាមនិតិវិធីស្របច្បាប់សំរាប់ការពារសហគមន៍រងផលប៉ះពាល់ និងបរិស្ថាននោះទេ។ ដីសម្បទានជាច្រើនពុំទាន់បានប្រើប្រាស់ដីអោយមានផលិតភាពនៅឡើយទេ តែត្រូវបានគេមើលឃើញថាជាការរំពឹងថ្លៃទៅថ្ងៃអនាគត ឬជាយន្តការសំរាប់បំរើការងារកាប់ឈើខុសច្បាប់ទៅវិញ។ ជាមួយគ្នានេះដែរ រហូតមកដល់ពេលនេះ រាជរដ្ឋាភិបាលបានខកខានមិនបានដំណើរការផែនការបង្កើតអោយមានដីសម្បទានសង្គមកិច្ចសំរាប់ប្រជាកសិករដែលគ្មានដីធ្លី តាមរយៈយន្តការមួយដែលមានតម្លាភាព និងការចូលរួម ក្រៅតែអំពីគំរោងសាកល្បងនៅខេត្តកំពង់ចាម និងខេត្តក្រចេះនោះឡើយ។

ស្រដៀងគ្នានេះដែរ **ធនធានជលផលទឹកសាប** ដែលផ្គត់ផ្គង់ជីវភាពរស់នៅ និងផ្តល់សន្តិសុខស្បៀងដល់ប្រជាជនកម្ពុជារាប់លាននាក់ កំពុងស្ថិតក្នុងការគំរាមកំហែងនៅតាមតំបន់មួយចំនួន ដែលបណ្តាលមកពីការចាក់បំ-ពេញដីរបស់ក្រុមហ៊ុនទៅក្នុងតំបន់ព្រៃលិចទឹកដែលជាជំរកត្រីពងយ៉ាងសំខាន់របស់មច្ឆជាតិ។

ជាងនេះទៅទៀតប្រជាជនក្រីក្រ និងគ្រួសារងាយរងគ្រោះ នៅតែទទួលរងនូវការ**រឹបអូសដីធ្លី** ហើយស្ថាប័នរដ្ឋាភិបាលដែលទទួលខុសត្រូវដោះស្រាយទំនាស់ដីធ្លី នៅតែមិនទាន់មានប្រសិទ្ធិភាព។ **ជនជាតិដើមភាគតិច** ជាពិសេសនៅតំបន់ភូមិភាគឦសាននៅតែបន្តបាត់បង់ដីធ្លី ទោះបីជាច្បាប់ភូមិបាលឆ្នាំ២០០១ បានការពារចំពោះដីសមូហភាពជនជាតិដើមភាគតិចក៏ដោយ។ ប្រាំមួយឆ្នាំក្រោយពីអនុម័តច្បាប់ភូមិបាលរួចមក ការចុះបញ្ជីកម្មសិទ្ធដីសមូហភាពកំពុងស្ថិតនៅក្នុងដំណាក់កាលសាកល្បងនៅឡើយ ហើយឆន្ទៈនយោបាយក្នុងការអនុវត្តន៍ការចុះបញ្ជីនៅមានភាពទន់ខ្សោយនៅឡើយ។

ជនជាតិដើមភាគតិចនៅភាគឦសានធ្លាប់ទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ទាំងទ្រព្យសម្បត្តិ សម្ភារៈអាយុជីវិត ដោយ**ការអភិវឌ្ឍន៍ថាមពលវារីអគ្គីសនី** នៅប្រទេសឡាវ និងប្រទេសវៀតណាម ហើយពួកគេពុំបានទទួលសំណងពីអ្វីបន្តិចសោះឡើយ។ គំរោងថាមពលវារីអគ្គីសនីមួយចំនួន កំពុងចាប់ផ្តើមនៅក្នុងប្រទេសកម្ពុជាដែលនាំអោយមានការភ័យខ្លាច ដោយសារតែរាជរដ្ឋាភិបាលកម្ពុជា ខកខានមិនបានពិចារណាម្តងហើយម្តងទៀតអំពីផលប៉ះពាល់ដល់សង្គម និងបរិស្ថានរបស់គំរោងអភិវឌ្ឍន៍ទាំងនោះ។ បញ្ហានេះនៅតែបន្តមាននៅក្នុងគំរោងទាំងនេះដោយទុកអោយប្រជាជនក្រីក្រ និងជនងាយរងគ្រោះ នៅតែបន្តខាតបង់ចំពោះការរីកចំរើនសេដ្ឋកិច្ច ដោយសារការមិនបានគិតពិចារណាអោយបានសមរម្យពីបញ្ហាសមធម៌។

ការធ្លាក់ចុះនៃសិទ្ធិប្រើប្រាស់ដី និងធនធានធម្មជាតិ បានធ្វើអោយ**ជីវភាពរស់នៅរបស់ប្រជាជន** ដែលធ្លាប់មាននិរន្តរភាពជាច្រើនជំនាន់មកហើយនោះ ត្រូវបាត់បង់ដោយគ្មានបន្សល់ទុកនូវជំរើសជីវភាពថ្មីឡើយ។ នេះជាហេតុផលធ្វើអោយភាពក្រីក្រមានការកើនឡើង **សន្តិសុខស្បៀង**ថយចុះ ហើយគំលាតរវាងអ្នកមាន និងអ្នកក្រនៅក្នុងសង្គមកម្ពុជាកាន់តែរីកធំឡើងៗ។ និន្នាការទាំងនេះធ្វើអោយគោលដៅរបស់យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិមិនអាចសំរេចទៅបាន និងត្រូវផ្តោតយកចិត្តទុកដាក់លើឧបសគ្គគន្លឹះចំពោះអភិបាលកិច្ចល្អ គណនេយ្យភាព និងការកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជា។

អ្វីដែលត្រូវការចាំបាច់បំផុតក្នុងការអភិវឌ្ឍន៍កម្ពុជា អោយមានការឆ្លើយតបចំពោះតំរូវការរបស់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះនោះ គឺ**ឆន្ទៈនយោបាយក្នុង**ការអនុវត្តន៍ច្បាប់។ អនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច

ចែងថា មុនពេលប្រគល់ដីសម្បទានស្ដេកិច្ចទៅអោយក្រុមហ៊ុនឯកជន ដីនោះត្រូវមានការចុះបញ្ជីជាសម្បត្តិឯកជនរបស់រដ្ឋជាមុនសិន និងត្រូវធ្វើការវាយតំលៃចំពោះហេតុប៉ះពាល់សង្គម និងបរិស្ថាន ព្រមទាំងធ្វើការពិគ្រោះយោបល់ជាសាធារណៈជាមួយសហគមន៍ដែលរងប៉ះពាល់។ ស្ទើរតែគ្រប់ករណីទាំងអស់ គេពុំបានអនុវត្តន៍ទៅតាមនីតិវិធីស្របច្បាប់ទាំងនោះទេ។

អង្គការមិនមែនរដ្ឋាភិបាល សូមផ្តល់ជាអនុសាសន៍ដល់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍របស់ខ្លួនដូចតទៅ:

១. ប្រញាប់ធ្វើការកំណត់ព្រំដី និងធ្វើការចុះបញ្ជីដីរដ្ឋ និងផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាព របស់ជនជាតិដើមភាគតិច ដោយអនុវត្តតាមដំណើរការមួយដែលមានការចូលរួម និងមានតម្លាភាព។

២. ផ្អាកការផ្តល់ និងការប្រើប្រាស់ដីសម្បទានសេដ្ឋកិច្ចជាបណ្តោះអាសន្ន រហូតដល់ដីឯកជនរបស់រដ្ឋត្រូវបានកំណត់ព្រំដី និងមានចុះបញ្ជីស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ និងមានការចុះបញ្ជីផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពសហគមន៍ជនជាតិដើមភាគតិចបានចប់សព្វគ្រប់សិន។

៣. ការបណ្តេញចេញអាចធ្វើទៅបានតែក្នុងករណីដែលជំរើសផ្សេងៗត្រូវបានលើកយកមកអនុវត្ត ហើយពុំបានផលតែប៉ុណ្ណោះ ប៉ុន្តែត្រូវបង្កើតអោយមានគោលនយោបាយមួយដែលជួយគាំទ្រចំពោះជំរើស "ចែកដី" នៅលើតំបន់អភិវឌ្ឍន៍ឡើងវិញ។ តំលៃសំណងគួរតែផ្តល់អោយបានសមរម្យ និងយុត្តិធម៌ដល់ប្រជាជនរងគ្រោះ នៅមុនពេលការចាប់ផ្តើមអនុវត្តគំរោងទៅតាមតំលៃទីផ្សារ ដោយមានការវាយតំលៃដោយអ្នកអង្កេតការ/តាមដានឯករាជ្យ ហើយសំណងទាំងនោះត្រូវអោយសមស្របទៅតាមតំលៃសរុប ដើម្បីការពារសិទ្ធិរបស់ពួកគេ ដូចមានចែងនៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ (មាត្រាទី ៤៤) និងក្នុងច្បាប់ភូមិបាលឆ្នាំ២០០១។

៤. លើកកំពស់សមត្ថភាពរបស់គណៈកម្មាធិការសុរិយោដីក្នុងការដោះស្រាយករណីទំនាស់ដីធ្លីជាពិសេសនៅថ្នាក់ស្រុក និងបែងចែកច្បាស់លាស់ពីដែនសមត្ថកិច្ចរបស់អាជ្ញាធរជាតិ ដោះស្រាយទំនាស់ដីធ្លីអោយសមស្របទៅតាមគោលការណ៍នីតិរដ្ឋ។

៥. ណែនាំនូវគំរូនៃការអភិវឌ្ឍន៍កសិកម្ម ដែលមានការគាំទ្រដល់ជនក្រីក្រ ដោយទុកធនធានធម្មជាតិអោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់កសិករកម្ពុជាដោយផ្ទាល់។ គួរផ្តល់អាទិភាពក្នុងការពង្រីកការផ្សព្វផ្សាយទៅដល់ប្រជាកសិករតូចតាច និងក្នុងការបង្កើនទិន្នផលកសិកម្មតាមរយៈការកែច្នៃនូវវិធីសាស្ត្រកសិកម្មដែលចំណាយដើមទុនតិច ឧទាហរណ៍ការដាំស្រូវមួយដើម។ លើសពីនេះទៅទៀតគួរមានការលើកំពស់ការពង្រីកមុខដំណាំនៅក្នុងប្រព័ន្ធកសិកម្មចំរុះ សំរាប់ជាយុទ្ធសាស្ត្រក្នុងការធ្វើអោយបញ្ហាអាហារូបត្ថម្ភ និងចំណូលរបស់គ្រួសារកសិករខ្នាតតូចមានភាពប្រសើរឡើង។

៦. ពន្លឿនដំណើរការក្នុងការទទួលស្គាល់ព្រៃឈើសហគមន៍ តំបន់ការពាររបស់សហគមន៍ និងដែននេសាទសហគមន៍។ ធ្វើយ៉ាងដូចនេះគឺដើម្បីអោយសិទ្ធិរបស់សហគមន៍ ក្នុងការទទួលបាននូវការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាពត្រូវបានការពារ។

៧. ផ្តល់ដីទំនេរ និងដីមិនមានព្រៃឈើដែលសមស្រប សំរាប់ប្រើប្រាស់ជាដីសម្បទានសង្គមកិច្ច តាមរយៈយន្តការមួយដែលមានការចូលរួម និងមានតម្លាភាព ដើម្បីធានាថាដីត្រូវបានប្រគល់អោយទៅក្រុមគ្រួសារដែលត្រូវការដីបំផុតពុំត្រូវពន្យាពេលទៀតទេ។

សំរាប់ព័ត៌មានបន្ថែម ស្តីពីបញ្ហាទាំងឡាយដែលលើកឡើងក្នុងផ្នែកខាងលើនេះ សូមអានឯកសារស្តីពីគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាល ស្តីពីការអភិវឌ្ឍន៍កម្ពុជាក្នុងឆ្នាំ២០០៦ នៅក្នុងជំពូកស្តីពីកំណែទម្រង់ដីធ្លី ព្រៃឈើ ចំការឈើដាំ និងដីសម្បទាន ការអភិវឌ្ឍន៍កសិកម្ម និងការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ បញ្ហាវិស័យជលផល និងការអភិវឌ្ឍន៍ថាមពលវារីអគ្គិសនី។

## ២.២ អភិបាលកិច្ចល្អ

### ការប្រយុទ្ធប្រឆាំងអំពើពុករលួយ

អង្គការមិនមែនរដ្ឋាភិបាល សូមកោតសរសើរចំពោះឆន្ទៈរបស់រាជរដ្ឋាភិបាល ក្នុងការដាក់បញ្ចូលបញ្ហាអភិបាលកិច្ចល្អទៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-២០១០ ប៉ុន្តែកត់សំគាល់ឃើញថា ភាពរីកចំរើនជាទូទៅមានភាពយឺតយ៉ាវ រីឯបញ្ហាកំណែទម្រង់មួយចំនួនដែលបានសន្យាត្រូវបានជាប់គាំង។

មិនខុសពីកាលកំណត់មុនៗទេ គឺថាកាលកំណត់សំរាប់ការបញ្ចប់ និងអនុម័ត**សេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ** កាលពីខែមិថុនា ឆ្នាំ២០០៦នោះ ត្រូវបានខកខានម្តងទៀត។ រយៈពេលមួយឆ្នាំក្រោយកាលកំណត់បានកន្លងផុតទៅ គេពិនិត្យឃើញថាមិនមានវឌ្ឍនភាពច្បាស់លាស់ណាមួយ នៅក្នុងដំណើរការតាក់តែងច្បាប់សោះឡើយ។ ចាប់តាំងពីពេលធ្វើសុខដុមនីយកម្មរវាងសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ និងក្រមនីតិវិធីព្រហ្មទណ្ឌរួចមក អង្គការមិនមែនរដ្ឋាភិបាលសង្កេតឃើញថា វាពុំមានឧបសគ្គក្នុងការអនុម័តសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួតឡើយ។ ទាក់ទងនឹងខ្លឹមសារនៃសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ អង្គការមិនមែនរដ្ឋាភិបាលទទួលស្គាល់ថា មានភាពប្រសើរឡើងមួយចំនួននៅក្នុងសេចក្តីព្រាងចុងក្រោយនេះ បើប្រៀបធៀបទៅនឹងសេចក្តីព្រាងឆ្នាំ២០០៣។ ទោះជាយ៉ាងណាក៏ដោយសេចក្តីព្រាងច្បាប់នេះ នៅតែមិនទាន់ស្របតាមនិយាមអន្តរជាតិដែលបានព្រមព្រៀងដោយរាជរដ្ឋាភិបាល និងភាគីម្ចាស់ជំនួយកាលពីកិច្ចប្រជុំពិគ្រោះយោបល់ឆ្នាំ២០០៤ នោះទេ។ អង្គការមិនមែនរដ្ឋាភិបាល សូមកោតសរសើរចំពោះការអនុញ្ញាតអោយសង្គមស៊ីវិលបានចូលរួមខ្លះៗ សំរាប់លើកដំបូង នៅក្នុងដំណើរការតាក់តែងច្បាប់ដ៏សំខាន់នេះ ហើយទទូចសូមអោយនៅបន្តមានការចូលរួមកាន់តែពេញលេញជាងមុនក្នុងពេលខាងមុខនេះ។

ការផុតកាលកំណត់សំខាន់មួយទៀត ដែលពុំទាន់បានធ្វើនៅឡើយនោះ គឺការបង្កើត**ក្របខ័ណ្ឌគោលនយោបាយស្តីពីសេរីភាពព័ត៌មាន**អោយបានច្បាស់លាស់។ ក្រៅពីសកម្មភាពខ្លះៗដែលក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ចបានធ្វើក្នុងកំឡុងពេលពិនិត្យឡើងវិញ ក្រសួងហាក់ដូចជាគ្មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការជំរុញអោយដំណើរការនេះឆ្ពោះទៅមុខឡើយ។ អង្គការមិនមែនរដ្ឋាភិបាលជំរុញអោយបញ្ចប់ក្របខ័ណ្ឌគោលនយោបាយស្តីពីសេរីភាពព័ត៌មាននេះនៅត្រឹមឆ្នាំនេះ។

របកកំហើញធនធានប្រេង និងឧស្ម័នដ៏ច្រើនសន្ធឹកសន្ធាប់ នាំអោយមានការព្រួយបារម្ភ ថាតើត្រូវធ្វើយ៉ាងណាដើម្បីអភិវឌ្ឍន៏វិស័យប្រេងកាតនៅកម្ពុជាអោយមានប្រសិទ្ធិភាពបំផុត ជាពិសេសទាក់ទងទៅនឹងការគ្រប់គ្រងចំណូលយ៉ាងសន្ធឹកសន្ធាប់ពីវិស័យនេះនាពេលអនាគត។ គេរំពឹងថា កម្ពុជានិងមិនពឹងផ្អែកលើជំនួយអភិវឌ្ឍន៍ពីបរទេសទៀតទេ ហើយសេដ្ឋកិច្ចប្រទេសនេះនិងលូតលាស់តាមមធ្យោបាយមួយ ដែលជំរុញអោយមានកំណើនសេដ្ឋកិច្ចខ្ពស់សំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។ ឆ្លងតាមបទពិសោធន៏ពីបណ្តាប្រទេស ដែលមានបានដោយសារធនធានធម្មជាតិដ៏គំហុក ទាមទារអោយមានការធ្វើផែនការយ៉ាងប្រុងប្រយ័ត្ន ដើម្បីធានាថាកំណើនដ៏គំហុកនៃប្រាក់ចំណូល និងចំណាយ មិនមានផលប៉ះពាល់ទៅលើបរិយាកាសម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍន៍សង្គម ឬស្ថិរភាពនយោបាយរបស់ប្រទេស។ អង្គការមិនមែនរដ្ឋាភិបាល ផ្តល់អនុសាសន៏សូមអោយរដ្ឋាភិបាលកម្ពុជាចូលជាសមាជិកនៃក្រុមផ្តួចផ្តើមគំនិតតម្លាភាពលើឧស្សាហកម្មនិស្សារណ (EITI) អោយបានឆាប់តាមការដែលអាចធ្វើទៅបាន។

**កំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ**

សហគមន៏អង្គការមិនមែនរដ្ឋាភិបាលទទួលស្គាល់ការរៀបចំឯកសារយុទ្ធសាស្ត្រ កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ហើយដែលបានបោះពុម្ពផ្សាយដោយរាជរដ្ឋាភិបាលកម្ពុជា កាលពីឆ្នាំ២០០៣ និងសូមសំដែងនូវចំណាប់អារម្មណ៍ចង់ឃើញការអនុវត្តន៏កម្មវិធីកំណែទម្រង់ទាំងនេះ អោយមានប្រសិទ្ធិភាព និងបានលទ្ធផលល្អនៅទូទាំងវិស័យ។ ដោយមូលហេតុថា ការគោរពនូវគោលការណ៍នីតិរដ្ឋមានសារៈសំខាន់សំរាប់ការអភិវឌ្ឍន៍ប្រកបដោយសមធម៌ និងនិរន្តរភាពយូរអង្វែងនៅកម្ពុជា សហគមន៏អង្គការមិនមែនរដ្ឋាភិបាល សូមស្នើអោយរាជរដ្ឋាភិបាល និងរដ្ឋសភាជាតិបន្តធ្វើកំណែទម្រង់ និងពង្រឹងស្ថាប័នដើម្បីលើកកំពស់នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្សនៅកម្ពុជា និងការគោរពច្បាប់រដ្ឋធម្មនុញ្ញ។

ឧទាហរណ៍ **ស្ថាប័នសំខាន់ៗដែលមានស្រាប់គួរតែធ្វើការកែទម្រង់មូលដ្ឋាន** ក្នុងនោះរួមទាំងគណៈកម្មការរៀបចំការបោះឆ្នោត ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រុមប្រឹក្សាធម្មនុញ្ញ។ រហូតមកដល់ពេលនេះអង្គការមិនមែនរដ្ឋាភិបាលសូមបញ្ជាក់ជាថ្មីបន្តទៀតថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ ដើម្បីធានានូវឯករាជ្យភាពរបស់តុលាការ និងអនុលោមភាពរបស់ច្បាប់ទាំងឡាយស្របតាមរដ្ឋធម្មនុញ្ញនោះទាមទារអោយការពង្រឹងស្ថាប័នទាំងនេះ ដើម្បីការពារទប់ទល់ការជ្រៀតជ្រែកពីស្ថាប័ននីតិប្រតិបត្តិ។ ដូច្នេះជាមូលដ្ឋានគ្រឺៈ ស្ថាប័នទាំងបីនេះចាំបាច់បំផុតត្រូវតែឯករាជ្យ និងមិនបំរើគណបក្សនយោបាយទាំងមុខងារ និងសមាជិកភាពរបស់ស្ថាប័ន។ នោះមានន័យថា ស្ថាប័នទាំងនេះត្រូវតែឯករាជ្យមិនបំរើគណបក្សនយោបាយ មានសមត្ថភាពធ្វើការ និងអាចជឿទុកចិត្តបាន។

បច្ចុប្បន្នមានច្បាប់ជាច្រើនដែលកំពុងប្រើប្រាស់នៅក្នុងប្រព័ន្ធតុលាការកម្ពុជា ហើយច្បាប់ទាំងនោះសុទ្ធសឹងជាច្បាប់ដែលបានអនុម័តអោយប្រើប្រាស់ នៅមុនពេលកម្ពុជាចូលជាសមាជិករបស់អនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា និងមុនពេលចូលជាធរមាននៃច្បាប់រដ្ឋធម្មនុញ្ញបច្ចុប្បន្ននេះ។ មូលហេតុនេះបានបណ្តាលអោយ**ច្បាប់ទាំងនេះពុំអនុលោមទៅតាមកាតព្វកិច្ចរបស់កម្ពុជាចំពោះអនុសញ្ញាអន្តរជាតិ និងគោលការណ៍ច្បាប់** ដែលបានទទួល

ស្គាល់នៅកម្ពុជា។ ដូច្នេះរាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវដោះស្រាយបញ្ហាដែលស្របគ្នាទាំងនេះ អោយបានឆាប់រហ័ស និងត្រូវបង្កើតច្បាប់ថ្មីៗថែមទៀត ដើម្បីធានាថាប្រព័ន្ធច្បាប់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហាសំខាន់ៗដែលកំពុងបន្តមាន។ នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ក្នុងឆ្នាំ២០០៤ បញ្ហានេះត្រូវបានសំរេច និងព្រមព្រៀងថា ទីស្តីការគណៈរដ្ឋមន្ត្រីនឹងអនុម័តច្បាប់សំខាន់ៗចំនួនប្រាំបី ហើយត្រូវបញ្ជូលទៅរដ្ឋសភាជាតិអោយបានត្រឹមបំណាច់ឆ្នាំ២០០៥។ ច្បាប់ទាំងនេះត្រូវតែមានការត្រួតពិនិត្យឡើងវិញ និងជជែកវែកញែកដោយសមាជិករដ្ឋសភា រាជរដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីធានាអោយបានថា ការអនុម័តច្បាប់ទាំងនេះអនុលោមទៅតាមច្បាប់រដ្ឋធម្មនុញ្ញ តាមនិយាមអន្តរជាតិ និងទៅតាមអនុសញ្ញាសិទ្ធិមនុស្សនានា ដែលកម្ពុជាបានព្រមព្រៀងព្រមទាំងដើម្បីធានាអោយមានការពង្រឹងនីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យយ៉ាងពិតប្រាកដ។

ដោយមានការឧបត្ថម្ភគាំទ្រពីដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល សូមផ្តល់អនុសាសន៍មួយចំនួនចំពោះរាជរដ្ឋាភិបាលដូចតទៅ :

១. បន្តរៀបចំសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយចុងក្រោយនេះអោយស្របទៅតាមនិយាមអន្តរ-ជាតិ និងត្រូវអនុម័តច្បាប់នេះអោយបានត្រឹមមុនដំណាច់ឆ្នាំ២០០៧។

២. បញ្ចប់ការរៀបចំក្របខ័ណ្ឌគោលនយោបាយ ស្តីពីសេរីភាពសារព័ត៌មានអោយបានចប់សព្វគ្រប់នៅក្នុងឆ្នាំ២០០៧នេះ។

៣. ពិនិត្យឡើងវិញនូវប្រព័ន្ធរាយការណ៍ពីករណីអំពើពុករលួយ ដើម្បីទទួលបាននូវប្រព័ន្ធរាយការណ៍ដែលទៀងទាត់ មានរចនាសម្ពន្ធ័ច្បាស់លាស់ និងមិនលំអៀង។

៤. ចូលជាសមាជិករបស់ EITI អោយបានឆាប់តាមដែលអាចធ្វើទៅបាន។

៥. ធានាថាក្រសួងយុត្តិធម៌ និងភាគីពាក់ព័ន្ធ បញ្ចប់ និងអនុម័តច្បាប់សំខាន់ៗ ដែលមានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍នេះ។ **ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការ** និងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម គួតែដាក់ជាអាទិភាពសំរាប់ធ្វើការអនុម័ត។

៦. ដើម្បីធានាអោយបាននូវឯករាជ្យភាពរបស់តុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម គួរតែចែងអោយច្បាស់ថា "ចៅក្រមត្រូវតែជាជនដែលមិនមែនជាសមាជិកគណបក្សនយោបាយ និងមិនមានជាប់ពាក់ពន្ធ័នឹងកិច្ចការនយោបាយឡើយ"។

សំរាប់ព័ត៌មានបន្ថែមស្តីពីបញ្ហាដែលបានលើកឡើងក្នុងជំពូកនេះសូមអានសេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលស្តីពីការអភិវឌ្ឍន៍កម្ពុជាក្នុងឆ្នាំ២០០៦ នៅក្នុងជំពូកស្តីពីការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងជំពូកស្តីពីក្របខ័ណ្ឌច្បាប់ និងតុលាការ។

## ២.៣ ការអភិវឌ្ឍន៍ធនធានមនុស្ស

### វិស័យអប់រំ

បញ្ហាអាទិភាពសំខាន់ចំនួនពីរនៅក្នុងវិស័យអប់រំនៅកម្ពុជាគឺ:

១. ការផ្តល់ហិរញ្ញប្បទានគ្រប់គ្រង និងការបើកសាច់ប្រាក់របស់ថវិកាអប់រំបានទៀងពេលវេលា និង

២. លុបបំបាត់ឧបសគ្គចូលរៀនរបស់កុមារទាំងអស់។

ដើម្បីធានាថា គោលដៅអប់រំសំរាប់ទាំងអស់គ្នាអាចសំរេចទៅបាននោះ ទាមទារអោយមានការឧបត្ថម្ភថវិកាគ្រប់គ្រាន់សំរាប់វិស័យនេះ ហើយត្រូវធានាថា ថវិកាអប់រំត្រូវបានបើកសាច់ប្រាក់បានតាមពេលវេលា និងទៀងទាត់។ ការបញ្ចេញសាច់ប្រាក់របស់ថវិកាអប់រំមានការយឺតយ៉ាវ ធ្វើអោយប៉ះពាល់ដល់ការផ្តល់សេវាអប់រំនៅមូលដ្ឋាន ហើយបានបង្កអោយមានបញ្ហាជាច្រើន ចំពោះការផ្តល់សេវាអប់រំប្រកបដោយគុណភាព និងប្រសិទ្ធិភាព។

អង្គការមិនមែនរដ្ឋាភិបាលមានការព្រួយបារម្ភថា ការថយចុះនៃអត្រាគង់វង្សដល់ថ្នាក់ទី៦ នឹងធ្វើអោយការសំរេចគោលដៅអប់រំសំរាប់ទាំងអស់គ្នានៅកំរិតបឋមសិក្សា (ថ្នាក់ទីប១-៦) ត្រឹមឆ្នាំ២០១០ និងនៅកំរិតអប់រំមូលដ្ឋាន (ថ្នាក់ទី ១-៩) មិនអាចសំរេចបាន។

ការទទួលបាននូវការអប់រំត្រូវតែចាត់ទុកថាជាសិទ្ធិរបស់កុមារកម្ពុជាគ្រប់ៗរូប "ដោយមិនប្រកាន់ឋានៈ ទីកន្លែង ពូជសាសន៍ សាសនា ភាសា ភេទ ឬពិការភាពឡើយ"[2]។ ដើម្បីសំរេចទិសដៅនេះបាន ចាំបាច់**ត្រូវតែលុបបំបាត់រាល់ឧបសគ្គនៃការចូលរៀនទាំងអស់។** ជាពិសេសត្រូវដោះស្រាយបញ្ហានៃការបង់ប្រាក់របស់ឪពុកម្តាយក្នុងវិស័យអប់រំ និងលុបបំបាត់ការចំណាយក្រៅផ្លូវការត្រឹមឆ្នាំ២០០៨ ដែលបានដៅទុក។ ដើម្បីដោះស្រាយបញ្ហាខាងលើនេះបាន ចាំបាច់ត្រូវតំឡើងប្រាក់បៀវត្សរ៍គ្រូបង្រៀនអោយបានគ្រប់គ្រាន់ ដើម្បីលុបបំបាត់នូវការទារប្រាក់ក្រៅផ្លូវការ។ រហូតមកដល់ពេលនេះ ការកើតឡើងនៃការចំណាយក្រៅផ្លូវការនេះ គឺជាការបំពេញបង្គ្រប់ទៅនឹងប្រាក់បៀវត្សរ៍ដ៏តិចតួចសំរាប់សេវាសាធារណៈ។

### វិស័យសុខាភិបាល

ទោះបីជាការអង្កេតសុខភាពប្រជាសាស្ត្រកម្ពុជា (CDHS) ឆ្នាំ២០០៥ បានបង្ហាញពីវឌ្ឍនភាពរបស់វិស័យសុខាភិបាលក៏ដោយ ក៏អង្គការមិនមែនរដ្ឋាភិបាល (តំណាងដោយអង្គការមេឌីខាំ) មានការព្រួយបារម្ភយ៉ាងខ្លាំងពីសមត្ថភាពរបស់កម្ពុជា ដើម្បីឈានទៅសំរេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាក្នុងការកាត់បន្ថយអោយបានពីរភាគបីនៃអត្រាមរណៈភាពមាតា និងការកាត់បន្ថយអត្រាមរណៈរបស់កុមារ ក្រោមអាយុ ៥ឆ្នាំ ត្រឹមឆ្នាំ ២០១៥។ មាតា ទារកដែលទើបនឹងកើត និងសុខភាពកុមារ ជាបញ្ហាមិនអាចកាត់ផ្តាច់ចេញពីគ្នាបាន។ ដូច្នេះ ការបន្តផ្តល់សេវាថែទាំសុខភាពសំរាប់មាតា ទារកដែលទើបនឹងកើត និងកុមារ ត្រូវតែបង្កើតឡើង និងអនុវត្តដោយមានការគាំទ្រថវិកាគ្រប់គ្រាន់ប្រកបដោយនិរន្តរភាព។

---

[2] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-១០ (ចំណុចទី ៤.៨៥)

ពាក់ព័ន្ធនឹង**សុខភាពមាតា** មូលហេតុរួមនៃការស្លាប់របស់មាតា ដោយសារការពន្លូតកូន ពេលមានគតិមានការហូរឈាម ការសម្រាលកូនមិនរួច ការឆ្លងមេរោគក្នុងឈាម និងព្រាយក្រឡាភ្លើង។ នៅថ្នាក់មូលដ្ឋានសុខាភិបាលវិញ នៅមានការងារជាច្រើនដែលត្រូវតែធ្វើការកែលំអ និងពង្រីកលទ្ធភាពទទួលបាន និងគុណភាពនៃសេវាសម្រាលកូនសង្គ្រោះបន្ទាន់។ នៅកំរិតសហគមន៍ ស្ត្រីជាមាតាដែលទទួលរងនូវបញ្ហាទាំងនេះនឹងត្រូវស្លាប់ដោយពុំបានទទួលសេវាសម្រាលកូនសង្គ្រោះបន្ទាន់នេះ។ បញ្ហាដ៏ធំបំផុតនោះស្ថិតត្រង់ថា តើធ្វើយ៉ាងណាដើម្បីអាចបញ្ជូនករណីធ្ងន់ធ្ងរទាំងនោះពីសហគមន៍ទៅកាន់មូលដ្ឋានសុខាភិបាល។ ភាគច្រើននៃប្រព័ន្ធបង្អែកនៅមូលដ្ឋានសុខាភិបាលមិនដំណើរការ ឬដំណើរការមិនល្អ។ អង្គការមេឌីខាំ សូមអំពាវនាវអោយមានការគាំទ្រលើការពង្រឹងប្រព័ន្ធបង្អែក ជាពិសេសពីថ្នាក់សហគមន៍ទៅកាន់មូលដ្ឋានសុខាភិបាល។

រីឯបញ្ហា**សុខភាពកុមារ**វិញ ការអង្កេតសុខភាពប្រជាសាស្ត្រកម្ពុជា ឆ្នាំ២០០៥ បង្ហាញថា កម្ពុជាបានបោះជំហានលឿនគួរសមក្នុងការឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា។ ទោះជាយ៉ាងណាក្តី អត្រាមរណៈរបស់ទារក និងកុមារក្រោមអាយុ ៥ឆ្នាំ នៅតែមានកំរិតខ្ពស់ ដែលមិនអាចទទួលយកបាន។ សព្វថ្ងៃយើងមានយន្តការ និងបទអន្តរាគមន៍ល្អៗ ក្នុងការដោះស្រាយមូលហេតុសំខាន់ៗនៃការស្លាប់នេះ។ យើងលើកជាសំនួរថាតើអ្វីខ្លះទៀតដែលត្រូវធ្វើដើម្បីកុំអោយកុមារនៅបន្តស្លាប់ទាំងអណោចអធមយ៉ាងដូច្នេះ។ យើងលើកបញ្ហានេះដើម្បីចង់អោយកម្ពុជាមានលទ្ធភាពអាចសម្រេចបាន នូវចំណុចដៅនៃអត្រាមរណៈទារក និងកុមារក្រោមអាយុ ៥ឆ្នាំ នៅឆ្នាំ២០១៥។

ឥឡូវនេះក្រសួងសុខាភិបាល បានបញ្ចប់ការរៀបចំ**យុទ្ធសាស្ត្ររស់រានរបស់កុមារកម្ពុជា**របស់ខ្លួនហើយ។ យុទ្ធសាស្ត្រនេះបានលើកឡើងនូវអន្តរាគមន៍ចំនួន១២ នៅក្នុងប័ណ្ណដាក់ពិន្ទុការរស់រានរបស់កុមារ ដែលបានសម្រាំងឡើងដើម្បីធ្វើអោយមានផលប៉ះពាល់ជាអតិបរមា លើការកាត់បន្ថយអត្រាស្លាប់របស់កុមារនៅកម្ពុជា។ បញ្ហាប្រឈមចំពោះមុខនាពេលបច្ចុប្បន្ននេះ គឺត្រូវធានាថាកុមារកម្ពុជាគ្រប់រូប អាចទទួលបាននូវអន្តរាគមន៍ទាំង១២ ដោយមិនគិតថាពួកគេរស់នៅទីណានោះទេ។ ឥឡូវនេះយុទ្ធសាស្ត្រត្រូវបានបង្កើតឡើង ហើយបញ្ហាអាទិភាពក៏បានកំណត់រួចដែរ អង្គការមេឌីខាំ សូមអំពាវនាវដល់ដៃគូអភិវឌ្ឍន៍ (ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល) និងរាជរដ្ឋាភិបាលអោយធ្វើការពង្រីក និងតំរង់កម្មវិធី និងធនធានរបស់ខ្លួន អោយសមស្របទៅតាមយុទ្ធសាស្ត្រ និងអាទិភាពទាំងនេះ។ យើងជាសហគមន៍អង្គការមិនមែនរដ្ឋាភិបាល បំរើការងារក្នុងវិស័យសុខាភិបាល សូមស្នើដល់ **ម្ចាស់ជំនួយ បង្កើនការគាំទ្រទៅលើបញ្ហាសុខភាពកុមារ និងបញ្ហាឆ្លងវិស័យដែលពាក់ព័ន្ធនឹងបញ្ហាកុមារ។**

យើងយល់ឃើញថា ការគាំត្រផ្នែកថវិកាសំរាប់សុខភាពមាតា ទារកទើបនឹងកើត និងសុខភាពកុមារ មិនត្រូវបានយកចិត្តទុកដាក់ទេកន្លងមក ជាពិសេសបើប្រៀបធៀបទៅនឹងជំនួយឧបត្ថម្ភសំរាប់ជំងឺឆ្លង ដូចជា មេរោគហ៊ីវ និងជំងឺអេដស៍ ជំងឺរបេង ជំងឺគ្រុនចាញ់ និងជំងឺឆ្លងដែលទើបលេចចេញថ្មីៗមួយចំនួនទៀត ដូចជាជំងឺផ្តាសាយបក្សីជាដើម។

ទន្ទឹមនឹងនោះ បញ្ហាប្រាក់បៀវត្សរ៍ទាប និងប្រាក់ឧបត្ថម្ភលើកទឹកចិត្តតិច សំរាប់បុគ្គលិកវិជ្ជាជីវៈសុខាភិបាល ចាំបាច់ត្រូវតែដោះស្រាយជាបន្ទាន់។ ការឆ្លើយតបទៅនឹងបញ្ហាពហុវិស័យដទៃទៀត ក៏ត្រូវការចាំបាច់ផង

ដែរដើម្បីប្រមូលផ្តុំលទ្ធភាពក្នុងការលើកកំពស់សុខភាពមាតា ទារកទើបនឹងកើត និងសុខភាពកុមារ ។ អន្តរាគមន៍ពហុវិស័យក៏គួរដាក់បញ្ចូលផងដែរនូវការពង្រីកការទទួលទានទឹកស្អាត អនាម័យ និងអាហារូបត្ថម្ភ ។

### សមភាពយេនឌ័រ

ភាគច្រើននៃក្រសួងពាក់ព័ន្ធសុទ្ធតែបានបង្កើនការយកចិត្តទុកដាក់ចំពោះតម្រូវការ និងការចូលរួមចំណែករបស់ស្ត្រី តាមរយៈការបង្កើតនូវក្របខ័ណ្ឌគោលនយោបាយស្ថាប័ន សំរាប់ជាយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ។ ទោះជាយ៉ាងដូចនេះក៏ដោយក៏ការអភិវឌ្ឍន៍ និងការអនុវត្តន៍នូវគោលនយោបាយទាំងនេះ ប្រើពេលយូរ ហើយហាក់ដូចជាស្ថិតក្រោមការជំរុញ និងដឹកនាំដោយម្ចាស់ជំនួយ ឬក៏អនុវត្តតែក្រសួងកិច្ចការនារីមួយប៉ុណ្ណោះ រីឯក្រសួងសាមុីវិញហាក់ដូចជាមានភាពជាម្ចាស់តិចតួចបំផុត ។ បញ្ហាយេនឌ័រជាទូទៅ មិនទទួលបានអាទិភាពខ្ពស់ទេក្នុងការសំរេចបាននូវគោលដៅអាទិភាព និងតម្រូវការផ្សេងៗ ។ កម្សោយផ្នែកអភិបាលកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុមិនបានល្អ គឺជាឧបសគ្គចំបងក្នុងការលើកកំពស់សមភាពយេនឌ័រ ។ បញ្ហាគន្លឹះ និងអនុសាសន៍ របស់សហគមន៍អង្គការមិនមែនរដ្ឋាភិបាលចំពោះបញ្ហានេះ គឺអំពាវនាវអោយរាជរដ្ឋាភិបាលធ្វើការកែលំអការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលើការបញ្ចេញសាច់ប្រាក់ថវិកាជាតិ ដូចមានចែងនៅក្នុងឯកសារស្តីពីគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាល ស្តីពីសមភាពយេនឌ័រ និងការកាត់បន្ថយភាពក្រីក្រ ។

ជារួមអង្គការមិនមែនរដ្ឋាភិបាល សូមផ្តល់អនុសាសន៍អោយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដូចខាងក្រោមៈ

១- ត្រូវធានាថា វិស័យអប់រំទទួលបានថវិកាគ្រប់គ្រាន់ និងការបញ្ចេញសាច់ប្រាក់បានទាន់ពេលវេលា និងទៀតទាត់ ដើម្បីបង្កអោយមានការផ្តល់សេវាបានល្អនៅថ្នាក់មូលដ្ឋាន ។

២- លុបបំបាត់រាល់ឧបសគ្គ ចំពោះការចូលរៀន ជាពិសេសត្រូវដោះស្រាយការបង់ប្រាក់របស់ឪពុកម្តាយ និងលុបបំបាត់ការបង់ប្រាក់ក្រៅផ្លូវការនៅត្រឹមឆ្នាំ២០០៨ ។ ដើម្បីសំរេចបញ្ហានេះ រដ្ឋាភិបាលត្រូវតំឡើងប្រាក់បៀវត្សរ៍គ្រូបង្រៀនអោយបានគ្រប់គ្រាន់ ដើម្បីលុបបំបាត់មូលហេតុនៃការបង់ប្រាក់ក្រៅផ្លូវការ ដែលបំពេញបង្គ្រប់ទៅអោយប្រាក់បៀវត្សរ៍តិចតួចរបស់មន្ត្រីរាជការ នាពេលបច្ចុប្បន្ន ។

៣- កែលំអ និងពង្រីកការទទួលបាននូវសេវា និងគុណភាពរបស់សេវា សម្រាលកូនសង្គ្រោះបន្ទាន់នៅឯកំរិតមូលដ្ឋានសុខាភិបាល ។

៤- ពង្រឹងប្រពន្ធ័បង្អែកសុខាភិបាល ជាពិសេសពីថ្នាក់សហគមន៍មកកាន់មូលដ្ឋានសុខាភិបាល ។

៥- ដោះស្រាយបញ្ហាប្រាក់បៀវត្សន៍ទាប និងប្រាក់ឧបត្ថម្ភតិចតួចសំរាប់បុគ្គលិកវិជ្ជាជីវៈសុខាភិបាល និងគ្រូបង្រៀន ។

៦- បន្សុីកម្មវិធី និងធនធានរបស់ខ្លួនទៅនឹងយុទ្ធសាស្ត្រការរស់រានរបស់កុមារ ។

៧- បង្កើនអន្តរាគមន៍តាមវិស័យទាក់ទងទៅនឹងការទទួលទានទឹកស្អាត អនាម័យ និងអាហាររូបត្ថម្ភ ។

៨- បង្កើនភាពជាម្ចាស់របស់សាមុីក្រសួងក្នុងការអនុវត្តន៍យុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ។

សំរាប់ព័ត៌មានបន្ថែមទាក់ទងនឹងបញ្ហាខាងលើ សូមអានឯកសារស្តីពីគោលជំហររបស់អង្គការមិនមែនរដ្ឋាភិបាល ចំពោះការអភិវឌ្ឍន៍របស់កម្ពុជាក្នុងឆ្នាំ២០០៦ នៅក្នុងជំពូកស្តីពីវិស័យអប់រំវិស័យសុខាភិបាល និងសមភាពយេនឌ័រក្នុងការកាត់បន្ថយភាពក្រីក្រ ។

## ៣. ផែនការអនាគត

សហគមន៍អង្គការមិនមែនរដ្ឋាភិបាល សូមសំដែងនូវការស្វាគមន៍ចំពោះឱកាស ក្នុងការចូលរួមជាមួយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ក្នុងការពិភាក្សាពីបញ្ហាអាទិភាព និងគោលនយោបាយអភិវឌ្ឍន៍របស់កម្ពុជា និងយុទ្ធសាស្ត្រនានា ក្នុងការអនុវត្តន៍តាមរយៈវេទិកាមួយចំនួន ដូចជា ក្រុមការងារបច្ចេកទេស (TWGs) គណៈកម្មាធិការសម្របសម្រួលម្ចាស់ជំនួយ និងរដ្ឋាភិបាល (GDCC) និងកិច្ចប្រជុំលើទីមួយរបស់វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) នេះ ។

សមគមន៍អង្គការមិនមែនរដ្ឋាភិបាល សង្ឃឹមថា វេទិកាទាំងនេះ នៅតែបន្តការយកចិត្តទុកដាក់ខ្ពស់ដល់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា ។ ទន្ទឹមនឹងនេះដែរអង្គការមិនមែនរដ្ឋាភិបាលទទួលស្គាល់ និងកោតសរសើរចំពោះបញ្ហាខាងលើនេះ ។ ការពិភាក្សាក៏រិតខ្ពស់នៅឯវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា នៅពេលអនាគត គួរតែផ្តោតជាសំខាន់លើចំនួនដ៏តិចតួចរបស់សូចនាករតាមដានរួមអាទិភាព ហើយក្រុមការងារបច្ចេកទេសចាំបាច់ត្រូវពិនិត្យតាមដានរាល់ទិដ្ឋភាពការងាររបស់ខ្លួននៅតាមវិស័យពាក់ពន្ធ័ ជាពិសេសដំណោះស្រាយចំពោះសូចនាករតាមដានរួមចាស់ ដែលមិនទាន់សំរេចបាន និងបញ្ហាថ្មីៗដែលពុំបានយកចិត្តទុកដាក់កន្លងមក ។ ខណៈដែលក្រុមការងារបច្ចេកទេសយល់ថា បញ្ហាសំខាន់ៗមិនទាន់បានដោះស្រាយនៅក្នុងកំរិតបច្ចេកទេសនៅឡើយនោះ បញ្ហាទាំងនេះទាមទារអោយមានការយកចិត្តទុកដាក់ និងធ្វើការជជែកពិភាក្សា ជាពិសេសនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលម្ចាស់ជំនួយ និងរដ្ឋាភិបាល និងចាំបាច់បំផុតនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ។